ការស្វែងយល់អំពីជីវិត

# ហេតុអ្វីបានជា ខ្ញុំឯកោយ៉ាងនេះ?

## ការស្វែងយល់ អំពីធាតុពិតនៃភាពឯកោ






**តើជីវិតរបស់អ្នកកំពុងតែជួបរឿងដដែលៗឬ?**
អ្នកក្រោកពីគេង ទៅធ្វើការ ត្រឡប់មកផ្ទះវិញ មើលទូរទស្សន៍ ឬទូរស័ព្ទ ហើយចូលគេង ហើយនៅថ្ងៃបន្ទាប់ អ្នកក៏ធ្វើដូចនេះទៀត។ ពុំនោះទេ ជីវិតរបស់អ្នកប្រហែលជាមិនមានភាពច្រំដែលដូចនេះទេ។ អ្នកប្រហែលជាកំពុងតែជាប់រវល់ធ្វើដំណើរទៅកន្លែងថ្មីៗ នៅថ្ងៃឈប់សម្រាក ឬកំពុងតែជាប់ចិត្តនឹងឧបករណ៍អេឡិចត្រូនិកថ្មីៗ ដែលកំពុងតែដាក់លក់នៅលើទីផ្សារ។

ទោះអ្នកកំពុងតែរស់នៅក្នុងភាពច្រំដែល ឬអត់ក៏ដោយ ខ្ញុំជឿថា អ្នកប្រាកដជាធ្លាប់ឆ្លងកាត់ភាពឯកោ។ ភាពឯកោអាចវាយប្រហារមកលើយើង សូម្បីតែនៅពេលដែលយើងកំពុងតែមានភាពរីករាយ និងសុខស្រួល។ មិត្តភក្តិខ្ញុំម្នាក់បានប្រាប់ខ្ញុំថា មានពេលមួយ គាត់មានការជួបជុំគ្នាដ៏ធំមួយ ជាមួយមិត្តភក្តិដែលធ្លាប់រៀនជាមួយគ្នា។ ស្ថិតក្នុងពេលដ៏អូអរនោះ គាត់ស្រាប់តែមានអារម្មណ៍ថា ឯកោខ្លាំងណាស់។ មិត្តភក្តិខ្ញុំម្នាក់ទៀត ក៏បានប្រាប់ខ្ញុំផងដែរថា គាត់មានការងារ មានផ្ទះ មានឡាន ក្រុមគ្រួសារ និងសម្ភារៈជាច្រើនដែលគាត់ចង់បាន តែគាត់នៅតែមានអារម្មណ៍ឯកោ។

ភាពឯកោជាបញ្ហាដែលកំពុងតែកើតមានជាទូទៅ ហេតុនេះហើយ ចក្រភពអង់គ្លេសក៏បានបង្កើតគណៈកម្មការមួយដើម្បីសិក្សាអំពីវា។ គណៈកម្មការនោះក៏បានធ្វើរបាយការណ៍ថា "ភាពឯកោបានកើតឡើងចំពោះមនុស្សទាំងអស់ ទាំងចាស់ទាំងក្មេង ដោយមិនរើសមុខ... យើងបានឮមនុស្សជាច្រើននិយាយអំពីភាពឯកោដែលពួកគេបានជួបប្រទះ។ អ្នកទាំងនោះមានដូចជា ឪពុកម្ដាយ កូន ជនពិការ អ្នកថែទាំអ្នកជម្ងឺ ជនភាសខ្លួន និងមនុស្សចាស់ ។ល។"

ចក្រភពអង់គ្លេសក៏បានឆ្លើយតប ចំពោះរបាយការណ៍នេះ ដោយចាត់តាំងឲ្យមានរដ្ឋមន្ត្រីក្រសួងឯកោ នៅឆ្នាំ ២០១៨។ លោកជំទាវថេរីសា មេយ (Theresa May) ដែលជានាយករដ្ឋមន្ត្រីនៃចក្រភពអង់គ្លេស បានមានប្រសាសន៍ នៅក្នុងសន្និសិទសារពត៌មានថា "សម្រាប់មនុស្សដ៏ច្រើនលើសលប់ ភាពឯកោគឺជារឿងពិត ដ៏សោកសៅ នៅក្នុងសម័យបច្ចុប្បន្ន"។

## ភាពឯកោ និងសម័យទំនើប

**ជាការពិតណាស់ របៀបនៃការរស់នៅក្នុងសម័យទំនើប** អាចធ្វើឲ្យមនុស្សកាន់តែមានភាពឯកោ។ សូមអនុញ្ញាតឲ្យខ្ញុំលើកយកមូលហេតុបីយ៉ាង ដូចតទៅ :

**ទីមួយ** វាជារឿងធម្មតាទេ ដែលនៅសម័យនេះ មានមនុស្សជាច្រើនបានធ្វើដំណើរទៅកន្លែងឆ្ងាយៗ ដើម្បីបំពេញការងាររបស់ខ្លួន ហើយថែមទាំងផ្លាស់ទៅរស់នៅ ក្នុងប្រទេសផ្សេង រយៈពេលពីរបីឆ្នាំ តាមការចាត់តាំងការងារ។ ការរស់នៅរបៀបនេះមិនមានរយៈពេលយូរទេ តែវាបានកាត់បន្ថយចំណងទាក់ទង ដែលយើងមានជាមួយទីកន្លែងដែលយើងស្រឡាញ់

និងជាមួយសាច់ញាតិ ឬមិត្តភក្តិដែលយើងមាន នៅកន្លែងទាំងនោះ។ ទោះអ្នកបានទៅដល់កន្លែងណាក៏ដោយ អ្នកប្រហែលមិនចង់ ឬមិនអាចបង្កើតមិត្តភាពដ៏ស្និតស្នេហ៍ ព្រោះអ្នកមិនដឹងថា ខ្លួនឯងនឹងនៅកន្លែងនោះយូរប៉ុណ្ណាទេ។ ការរំខានទាំងនេះអាចធ្វើឲ្យអ្នកមានអារម្មណ៍ថា កន្លែងទាំងនោះមិនមែនជាកន្លែងរបស់អ្នក ហើយគ្មាននរណាម្នាក់ស្គាល់អ្នកច្បាស់ទេ។

**ទីពីរ** យើងមានការពឹងផ្អែកទៅលើបច្ចេកវិទ្យាកាន់តែខ្លាំង ដែលមានដូចជា ទូរស័ព្ទទំនើប ថេបលេត និងកំព្យូទ័រជាដើម។ បច្ចេកវិទ្យាអាចនាំមកនូវការកម្សាន្តសប្បាយនៅក្នុងការប្រើប្រាស់ ប៉ុន្តែ វាបានធ្វើឲ្យយើងនៅដាច់ពីអ្នកដទៃកាន់តែខ្លាំង។ កាលណាយើងចំណាយពេលវេលា នៅពីមុខស្គ្រីនទូរស័ព្ទកាន់តែច្រើន នោះយើងក៏មានពេលកាន់តែតិច សម្រាប់បង្កើតទំនាក់ទំនងដ៏មានន័យ ជាមួយមនុស្សជុំវិញខ្លួនយើង។

យើងក៏ញៀននឹងបច្ចេកវិទ្យាកាន់តែខ្លាំង បានជាយើងសុខចិត្តចំណាយពេលនៅពីមុខស្គ្រីនទូរស័ព្ទ ជាជាងនៅពីមុខមនុស្ស។ ខ្ញុំបានសួរមិត្តភក្តិម្នាក់ថា ហេតុអ្វីបានជាគាត់ចំណាយពេលច្រើនយ៉ាងនេះ នៅលើបណ្តាញអ៊ីនធើណិត ជាជាងចំណាយពេលជួបមនុស្សដោយផ្ទាល់។ គាត់ឆ្លើយថា គាត់បានរកឃើញថា ការសន្ទនាមុខទល់នឹងមុខ និងការនៅក្បែរមនុស្ស ធ្វើឲ្យគាត់ចំណាយពេលច្រើន និងមានការនឿយហត់ ហើយពេលខ្លះ ធ្វើឲ្យគាត់មានការខកចិត្តផងដែរ។

តើនេះជាមូលហេតុ ដែលយើងសម្រេចចិត្តដកខ្លួន ទៅសង្ងំនៅពីមុខស្គ្រីនទូរស័ព្ទដែរឬ? យើងប្រហែលជាមិនដឹងទេថា ទោះការទំនាក់ទំនងមុខទល់នឹងមុខមានផលវិបាកយ៉ាង


យើងក៏ញៀននឹងបច្ចេកវិទ្យាកាន់តែខ្លាំង
បានជាយើងសុខចិត្តចំណាយពេលនៅពីមុខ
ស្គ្រីនទូរស័ព្ទ ជាជាងនៅពីមុខមនុស្ស។

ណាក្តី វានាំឲ្យមានអត្ថប្រយោជន៍ច្រើនជាងការទំនាក់ទំនងតាមអ៊ីនធើណិត ដែលច្រើនតែមានរយៈពេលខ្លី មិនពេញលក្ខណៈជាការទំនាក់ទំនង ហើយពេលខ្លះ យើងមិនស្គាល់អត្តសញ្ញាណគេទៀត។ ការទំនាក់ទំនងតាមអ៊ីនធើណិតកម្រនឹងធ្វើឲ្យយើងមានការពេញចិត្តនឹងការសន្ទនាគ្នា រៀងរាល់លើក ទោះវាហាក់ដូចជាមានហានីភ័យ តិចជាងការទំនាក់ទំនងមុខទល់នឹងមុខក៏ដោយ។

**ទីបី** យើងប្រហែលជាពិបាកទទួលស្គាល់ថា យើងកំពុងតែមានភាពឯកោ សូម្បីតែនៅចំពោះមុខអ្នកដែលជិតស្និទ្ធបំផុត។ ពេលយើងជួបមិត្តភក្តិ ហើយសួរសុខទុក្ខពួកគេថា "សុខសប្បាយទេ?" តើយើងរំពឹងថា ពួកគេនឹងឆ្លើយថា "ខ្ញុំឯកោ ឯកោខ្លាំងណាស់!" ឬ?

ក្នុងវប្បធម៌សព្វថ្ងៃ គេច្រើនតែគិតថា ភាពឯកោគឺជាចំណុចខ្សោយដ៏គួរឲ្យខ្មាស់អៀន ឬជាលក្ខណៈសម្បត្តិរបស់មនុស្សបរាជ័យ។ នៅក្នុងសង្គម យើងបានទទួលរងសម្ពាធ ឲ្យបង្ហាញចេញនូវសុភមង្គល ភាពមានតម្លៃ និងជោគជ័យរបស់យើង។ មនុស្សជាទូទៅ ចូលចិត្តធ្វើឲ្យគេគិតថា ខ្លួនមានជីវិតដ៏អស្ចារ្យ ឬបង្អួតខោអាវ ឬឧបករណ៍អេឡិចត្រូនិចថ្មីៗ និងជជែកគ្នាអំពីកាហ្វេប្រេនៗ និងកន្លែងដើរលេងល្បីៗ។ ដូចនេះពួកគេក៏បានប្រើទូរស័ព្ទ ដើម្បីបង្ហោះរូបភាព ដែលធ្វើឲ្យអ្នកដទៃគិតថា ខ្លួនមានភាពសម្បូរសប្បាយ។ ហើយពួកគេក៏ព្យាយាមថតរូបខ្លួនឯង និងរើសយកតែរូបណាមានសម្រស់ស្អាត ឬមានរបៀបរៀបរយ។

ប៉ុន្តែ តើការធ្វើដូចនេះ បានធ្វើឲ្យជីវិតយើងមានភាពល្អ

ប្រសើរឬទេ? តើរូបភាពដែលយើងបង្ហោះឲ្យគេមើល និងរូបភាពពិតរបស់យើង មានភាពខុសគ្នាប៉ុណ្ណា? ទំនោរមួយនេះបានជំរុញឲ្យយើងមិនចង់និយាយប្រាប់គេថា យើងកំពុងតែមានភាពឯកោ។ ដូចនេះយើងក៏មានភាពឯកោកាន់តែខ្លាំង។ ហើយពេលណានរណាម្នាក់បង្ហោះរូប នៅលើបណ្ដាញសង្គមដែលហាក់ដូចជាល្អឥតខ្ចោះ យើងក៏អាណឹតខ្លួនឯង ហើយក៏បានធ្លាក់ចូលទៅក្នុងភាពឯកោកាន់តែជ្រៅ។

## ធាតុពិតនៃភាពឯកោ

**ពេលអ្នកមានអារម្មណ៍ឯកោ** នោះត្រូវគិតថា វាជារឿងធម្មតាទេ។ ព្រះជាម្ចាស់បានបង្កើតយើងមក ឲ្យមានចិត្តដែលចង់បានការទំនាក់ទំនងដ៏មានន័យជាមួយព្រះអង្គ និងជាមួយអ្នកដទៃ។ ព្រះអង្គបានបង្កើតយើងមក ឲ្យមានអ្នករួមដំណើរដ៏មានន័យជាមួយយើង ហើយបានបង្កើតយើងមក ដើម្បីចែករំលែកជីវិតយើង ជាមួយអ្នកដទៃ តាមរបៀបដ៏មានន័យ។ ដូចនេះ ការមានអារម្មណ៍ឯកោ គឺជាការឆ្លើយតបដ៏ត្រឹមត្រូវ ពេលណាយើងមានអារម្មណ៍ថា យើងកំពុងតែខ្វះអ្វីមួយហើយ។

តាមព្រះគម្ពីរប៊ីប ដែលជាគោលនៃសេចក្ដីជំនឿរបស់គ្រីស្ទបរិស័ទ ភាពឯកោ គឺជាបញ្ហាទីមួយ ដែលព្រះជាម្ចាស់បានទតឃើញ នៅក្នុងជីវិតរបស់មនុស្សដំបូងដែលព្រះអង្គបានបង្កើត។ គ្រីស្ទបរិស័ទជឿថា ព្រះគម្ពីរប៊ីបគឺជាព្រះបន្ទូលព្រះ ហើយព្រះគម្ពីរប៊ីបបានចែងថា ព្រះជាម្ចាស់បានបង្កើតពិភពលោកទាំងមូល រួមទាំងសត្វ និងរុក្ខជាតិទាំងអស់ ព្រមទាំងមនុស្សប្រុសម្នាក់។ ពេលព្រះអង្គបានបង្កើតពួកគេហើយ ព្រះអង្គបានមានបន្ទូលថា អ្វីៗសុទ្ធតែល្អប្រសើរ។ តែព្រះអង្គក៏ជ្រាបផងដែរថា

"ដែលឲ្យមនុស្សប្រុសនៅតែឯង នោះគឺមិនល្អទេ"។ ដូចនេះ ព្រះអង្គជ្រាបថា ភាពឯកោគឺជាបញ្ហាចម្បងរបស់មនុស្សជាតិ។

ព្រះអង្គក៏បានដោះស្រាយបញ្ហានេះ ដោយបង្កើតគ្រួសារដំបូងបំផុត ដោយបង្កើតនាងអេវ៉ា ឲ្យធ្វើជាភរិយារបស់អ័ដាម។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាមួយទៀតក៏បានកើតឡើង នៅពេលដែលអ័ដាម និងនាងអេវ៉ាត្រូវវិញ្ញាណអាក្រក់ល្បួងឲ្យបះបោរទាស់នឹងព្រះ។

ពួកគេក៏បានសម្រេចចិត្តមិនស្តាប់បង្គាប់ព្រះអង្គ។ ការមិនស្តាប់បង្គាប់ព្រះ គឺជាអំពើបាប ហើយដោយសារអំពើបាបបានចូលមកក្នុងលោកិយ សេចក្តីស្លាប់ និងការបែកបាក់ទំនាក់ទំនង ក៏បានចូលមកក្នុងលោកិយផងដែរ។

សព្វថ្ងៃនេះ ពិភពលោករបស់យើង នៅតែមានភាពបាក់បែក ដោយសារអំពើបាបរបស់មនុស្ស។ វាជាបញ្ហាដ៏ធ្ងន់ធ្ងរណាស់។ សូមយើងគិតអំពីប្រភពនៃទុក្ខលំបាក ការសោកសង្រេង និងការឈឺចាប់ ហើយអ្នកប្រហែលជាគិតថា បញ្ហាទាំងនេះបណ្តាលមកពី អំណួត ភាពលោភលន់ ភាពត្រេកត្រអាល ការច្រណែន ការហួបចុកជ្រុល និងភាពខ្ជិលច្រអូស។ អ្នកខ្លះបានហៅសេចក្តីអាក្រក់ទាំងនេះថា "អំពើបាបទាំង៧ដែលនាំឲ្យស្លាប់"។ អំពើបាបទាំងនេះ បានកើតចេញពីការបែកបាក់ទំនាក់ទំនងរវាងមនុស្ស និងព្រះ។ ហើយអំពើបាបទាំងនេះ អាចនាំឲ្យមនុស្សនៅដាច់ពីគេឯង និងមានភាពឯកោ។

អ្នកប្រហែលជាគិតថា អ្នកអាចជម្នះអារម្មណ៍ឯកោដោយគ្រាន់ចំណាយពេលជាមួយអ្នកដទៃ ឲ្យកាន់តែច្រើន


ភាពឯកោ គឺជាបញ្ហាទីមួយ ដែលព្រះជា
ម្ចាស់បានទតឃើញ នៅក្នុងជីវិតរបស់
មនុស្សដំបូងដែលព្រះអង្គបានបង្កើត។

ហើយកុំធ្វើការ ឬធ្វើដំណើរច្រើនពេក ឬគ្រាន់តែទំនាក់ទំនងមុខទល់នឹងមុនឲ្យបានច្រើនជាង ការទំនាក់ទំនងតាមអ៊ីនធើណិត ឬក៏គ្រាន់តែប្រាប់គេថា ខ្លួនកំពុងតែមានអារម្មណ៍ឯកោ ជាជាងលាក់បាំងអារម្មណ៍មិនឲ្យគេដឹង ដោយខ្លាចខ្មាស់គេ។ ដំណោះស្រាយទាំងនេះ អាចពង្រឹងទំនាក់ទំនងជាមួយអ្នកដទៃ ប៉ុន្តែ វាមិនបានផ្តល់ដំណោះស្រាយ សម្រាប់ទំនាក់ទំនងដែលបានបែកបាក់រវាងមនុស្សនឹងព្រះ ដែលជាចំណុចស្នូលនៃភាពឯកោនោះឡើយ។

សរុបមក មនុស្សម្នាក់ៗមានភាពឯកោខាងវិញ្ញាណ ដែលកើតឡើងពីការបែកបាក់ទំនាក់ទំនង ជាមួយព្រះ ដោយសារអំពើបាបរបស់ខ្លួន។ យើងចាំបាច់ត្រូវផ្សះផ្សាទំនាក់ទំនងជាមួយព្រះជាម្ចាស់។

## ដំណោះស្រាយរបស់ព្រះជាម្ចាស់ សម្រាប់ភាពឯកោខាងវិញ្ញាណ

**សូមអរព្រះគុណព្រះអង្គ ដែលបានយកព្រះទ័យទុកដាក់ចំពោះ** បញ្ហានៃភាពឯកោខាងវិញ្ញាណរបស់យើង ដោយ ព្រះអង្គប្រទាននូវដំណោះស្រាយមួយ។ ព្រះគម្ពីរប៊ីបបានប្រាប់យើងថា ព្រះជាម្ចាស់បានប្រទានផ្លូវឲ្យយើងចេញពីភាពឯកោខាងវិញ្ញាណ។ វាជាអំណោយដែលកំពុងរង់ចាំឲ្យយើងទទួល ដោយឥតគិតថ្លៃ។ បើយើងបានទទួលអំណោយនេះយើង យើងនឹងមិនមានភាពឯកោខាងវិញ្ញាណទៀតឡើយ។

តើអំណោយនោះជាអ្វី? វាជាអំណោយនៃការផ្សះផ្សាជាមួយព្រះ ដោយយើងត្រូវទទួលជឿព្រះរាជបុត្រាព្រះអង្គ ព្រះនាមយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ និងព្រះសង្គ្រោះ។ មាន


សព្វថ្ងៃនេះ ពិភពលោករបស់យើង នៅតែមានភាពបាក់បែក ដោយសារអំពើបាបរបស់មនុស្ស។

តែអំណោយនេះទេ ដែលនឹងបញ្ចប់ភាពឯកោខាងវិញ្ញាណរបស់យើងបាន គឺគ្មានអ្វីផ្សេងទៀតដែលអាចធ្វើបានឡើយ។ យើងមិនអាចដោះស្រាយបញ្ហានៃភាពឯកោខាងវិញ្ញាណរបស់យើង ដោយខ្លួនឯងបានឡើយ។ យើងត្រូវការអំណោយនេះ ពីព្រះជាម្ចាស់។

មិត្តភក្តិរបស់ខ្ញុំបានពន្យល់ប្រាប់ខ្ញុំ ដោយយកផើងមួយធ្វើពីកញ្ចក់ ហើយក៏បានប្រាប់ខ្ញុំឲ្យធ្វើយ៉ាងម៉េច កុំឲ្យមានខ្យល់ចូលក្នុងផើងនោះបាន។ ខ្ញុំក៏ខំគិតយ៉ាងយូរ។ ខ្ញុំអាចបឺតខ្យល់ចេញពីក្នុងផើងនោះ ហើយគ្របវាឲ្យលឿន និងឲ្យណែន។ ទោះជាយ៉ាងណាក៏ដោយ ខ្យល់នៅតែអាចជ្រាតចូលទៅក្នុងផើងវិញដដែល។ ហើយពេលណាខ្ញុំមួលគំរប ខ្យល់នឹងចូលទៅក្នុងផើងនោះម្តងទៀត។ ដូចនេះ យើងហាក់ដូចជាគ្មានវិធីការពារមិនឲ្យខ្យល់ចូលទៅក្នុងផើងជារៀងរហូតឡើយ។

បន្ទាប់មក មិត្តភក្តិខ្ញុំក៏បានប្រាប់ដំណោះស្រាយ។ គាត់ថា "ដើម្បីកុំឲ្យខ្យល់ចូលទៅក្នុងផើងនោះវិញ យើងត្រូវបំពេញផើងនោះ ដោយសារជាតុអ្វីផ្សេង ដែលមានដូចជាទឹកជាដើម"។

យ៉ាងណាមិញ ជីវិតយើងក៏ស្រដៀងនឹងផើងនោះផងដែរ។ យើងប្រហែលជាព្យាយាមជម្នះភាពឯកោ ឬអំពើបាបដែលនាំឲ្យយើងមានភាពឯកោ។ យើងប្រហែលជាគិតថា "ដើម្បីជម្នះភាពឯកោ ខ្ញុំនឹងឈប់មានអំណួត! ឈប់មានភាពលោភលន់! បង្ក្រាបភាពត្រេកត្រអាល! ខ្ញុំនឹងបង្វែរអារម្មណ៍ខ្លួនឯង ឲ្យគិតរឿងផ្សេង ដើម្បីកុំខ្លួនខ្ញុំមានចិត្តប្រណែន! ខ្ញុំនឹងជម្នះភាពល្មោភស៊ី! ខ្ញុំនឹងបំបាត់កំហឹង! ខ្ញុំនឹងបង្ខំខ្លួនឯង ឲ្យបន្ថយភាពខ្ជិល"។

ប៉ុន្តែ ទោះយើងខិតខំការពារមិនឲ្យអំពើបាបចូលក្នុងជីវិតយើងយ៉ាងណាក៏ដោយ ក៏វានៅតែជ្រាតចូលដដែល គឺមិនខុសពីការដែលខ្យល់នៅតែជ្រាតចូលទៅក្នុងផើងនោះឡើយ។ ប៉ុន្តែ យើងមានដំណោះស្រាយមួយ។ យើងចាំបាច់ត្រូវបំពេញជីវិតយើង ដោយព្រះវត្តមានព្រះ គឺតាមរយៈការទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ។ ព្រះយេស៊ូវ "បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្តីទទឹងច្បាប់ ហើយនិងសំអាតមនុស្ស១ពួកទុកជាច់ជារាស្ត្ររបស់ផងទ្រង់ ដែលឧស្សាហ៍ធ្វើការល្អ" (ទីតុស ២:១៤)។ ព្រះអង្គនឹងជួយឲ្យយើងអាចជម្នះអំពើបាប ដែលបណ្តាលឲ្យយើងមានភាពឯកោខាងវិញ្ញាណ ហើយដែលសំខាន់បំផុតនោះ គឺព្រះអង្គនឹងយាងចូលគង់ ក្នុងជីវិតយើង ហើយបំពេញយើងដោយព្រះវត្តមានព្រះអង្គ។ ពេលណាយើងមានព្រះយេស៊ូវ ធ្វើជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង នោះយើងនឹងមិនមានភាពឯកោខាងវិញ្ញាណទៀតឡើយ។

## សន្និដ្ឋាន

**កាលបើយើងបានទទួលអំណោយនេះពីព្រះជាម្ចាស់ហើយ** យើងនឹងមិនចំបាច់ត្រូវមានការព្រួយបារម្ភទៀតឡើយ។ តើព្រោះហេតុអ្វី? ព្រោះយើងនឹងបានទទួលសេចក្តីស្រឡាញ់មួយរយភាគរយពីព្រះអង្គ ហើយព្រះអង្គក៏ស្គាល់យើងច្បាស់។ តើព្រះអង្គស្រឡាញ់យើងមួយរយភាគរយឬ? ជាការពិតណាស់ ព្រះជាម្ចាស់មិនគ្រាន់តែបានមានបន្ទូលថា ព្រះអង្គស្រឡាញ់យើងប៉ុណ្ណោះទេ តែព្រះអង្គក៏បានបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គ ដោយប្រទានដំណោះស្រាយដ៏ស្ថិត

ស្តេរមួយ សម្រាប់ភាពឯកោខាងវិញ្ញាណរបស់យើង។ តើព្រះអង្គស្គាល់យើងច្បាស់ឬ? ពិតមែនហើយ! ព្រះអង្គបានបង្កើតយើង នោះព្រះអង្គក៏ជ្រាបអំពីបំណងចិត្ត គំនិតដែលជ្រៅបំផុតព្រមទាំងជ្រាបអំពីផ្លូវរបស់យើង។ កាលណាយើងមានព្រះវត្តមានព្រះអង្គក្នុងជីវិតយើងហើយ នោះយើងមានការធានាអចិន្ត្រៃថា យើងនឹងមិននៅម្នាក់ឯងទៀតឡើយ ព្រោះព្រះអង្គនឹងដើរជាមួយយើង ទាំងនៅពេលយើងមានទុក្ខ ក៏ដូចជាពេលសប្បាយ។ ទោះយើងមានការលំបាកអ្វី ឬមានចំណុចខ្វះខាតយ៉ាងណាក៏ដោយ ព្រះអង្គបានធានាយើងថា ព្រះអង្គនឹងគង់នៅ និងស្រឡាញ់យើងជានិច្ច។


យើងនឹងមិននៅម្នាក់ឯងទៀតឡើយ ព្រោះ
ព្រះអង្គនឹងដើរជាមួយយើង ទាំងនៅពេល
យើងមានទុក្ខ ក៏ដូចជាពេលសប្បាយ។

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក សុខ គីម
ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។
រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2018 ODB Ministries ( website: www.odb.org )
ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@odb.org, Tell: 087 233 907, website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb )

**Our Daily Bread Ministries**

PO Box 15, Kilsyth, VIC 3137, Australia
Tel: (+61-3) 9761-7086, australia@odb.org
**Our Daily Bread Ministries Ltd**
PO Box 74025, Kowloon Central Post Office, Kowloon, Hong Kong
Tel: (+852) 2626-1102, Fax: (+852) 2626-0216, hongkong@odb.org
**ODB Indonesia**
PO Box 2500, Jakarta 11025, Indonesia
Tel: (+62-21) 2902-8950, Fax: (+62-21) 5435-1975,
indonesia@odb.org
**Daily Bread Co. Ltd**
PO Box 46, Ikoma Nara 630-0291, Japan
Tel: (+81-743) 75-8230, Fax: (+81-743) 75-8299, japan@odb.org
**Our Daily Bread Berhad**
PO Box 86, Taman Sri Tebrau, 80057 Johor Bahru, Malaysia
Tel: (+060-7) 353-1718, Fax: (+060-7) 353-4439, malaysia@odb.org
**Our Daily Bread Ministries**
PO Box 303095, North Harbour, Auckland 0751, New Zealand
Tel: (+64-9) 444-4146, newzealand@odb.org
**Our Daily Bread Ministries Asia Ltd**
5 Pereira Road, #07-01 Asiawide Industrial Building, Singapore 368025
Tel: (+65) 6858-0900, Fax: (+65) 6858-0400, singapore@odb.org
**Our Daily Bread Ministries Foundation**
PO Box 47-260, Taipei 10399, Taiwan R.O.C.
Tel: (+886-2) 2585-5340, Fax: (+886-2) 2585-5349, taiwan@odb.org
**Our Daily Bread Ministries Thailand**
PO Box 35, Huamark, Bangkok 10243, Thailand
Tel: (+66-2) 718-5166, Fax: (+66-2) 718-6016, thailand@odb.org